ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ: ០៤៧ អ.ក
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២០
សាលក្រមលេខ: ១១៣ "ជ"
ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០

# នាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ០៩ និង ០០ព្រឹក ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាចៅក្រមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាចៅក្រមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ជាតំណាងអយ្យការ នៃសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**មេធាវី**

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

កញ្ញា [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ០៤៧ អក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១.ជនជាប់ចោទឈ្មោះ [redacted] ចិត្ត ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល និងមានទីលំនៅបច្ចុប្បន្ននៅភូ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] អៀង (រស់) ម្តាយឈ្មោះ [redacted] រ៉ន (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន (ក្នុងឃុំ) ។

២.ជនជាប់ចោទឈ្មោះ [redacted] សក្កដា ហៅ កាក់ ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅភូមិ [redacted] ក្រុងភ្នំពេញ និងមានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួលក្នុងភូមិកំពង់សំណាញ់១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សុផល (រស់) ម្តាយឈ្មោះ [redacted] ស៊ីណាត (រស់) ប្រពន្ធឈ្មោះ [redacted] សុភ័ក្រនិច (រ) គ្មានកូន កម្រិតវប្បធម៌ រៀនថ្នាក់ទី១២ ជានីតិជន ទោសពីមុនគ្មាន (ក្នុងឃុំ) ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
កណ្តាល, ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០

[redacted]



Scanned with CamScanner

៣.ជនជាប់ចោទឈ្មោះ [redacted] សក្ករ៉ាផ ហៅ ពៅ ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅភូមិ [redacted] ក្រុងភ្នំពេញ និងមានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួលក្នុងភូមិកំពង់សំណាញ់១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សុផល (រស់) ម្ដាយ ឈ្មោះ [redacted] ស៊ីណាត (រស់) កម្រិតវប្បធម៌ រៀនថ្នាក់ទី៩ ជានីតិជន ទោសពីមុនគ្មាន (ក្នុងឃុំ) ។

៤.ជនជាប់ចោទឈ្មោះ [redacted] ចាន់ ហៅ ចាំង ភេទប្រុស អាយុ ១៥ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ ហ៊ិន (ស) ម្ដាយឈ្មោះ ពៅ (រ) នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន (ក្នុងឃុំ) ។

ត្រូវជាប់ចោទពីបទៈ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**ដំណាលរឿងហេតុមានដូចតទៅ ៖**

កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២០ ម៉ោង០០:៥០នាទី ខណៈពេលសមត្ថកិច្ចនៃអធិការដ្ឋាននគរបាលក្រុងតាខ្មៅ និងសមត្ថកិច្ចនគរបាលរដ្ឋបាលតាខ្មៅជិះល្បាតក្នុងភូមិសាស្ត្រដល់ចំណុចភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល បានឃើញជនត្រូវចោទចំនួន០៤នាក់ កំពុងអង្គុយក្បែរផ្លូវបេតុង ដោយមានការសង្ស័យ សមត្ថកិច្ចក៏ហៅជនត្រូវចោទឈ្មោះ [redacted] ចិត្ត មកសួរនាំនិងឆែកឆេរឃើញថ្នាំញៀនចំនួន០៤កញ្ចប់ ទើបធ្វើការឃាត់ខ្លួន។ បន្តមកទៀត សមត្ថកិច្ចបានរកឃើញថ្នាំញៀនចំនួន ០៥កញ្ចប់នៅក្បែរកន្លែងដែលជនត្រូវចោទឈ្មោះ [redacted] សក្កដា, ឈ្មោះ [redacted] សាក្ករ៉ាជ និងឈ្មោះ [redacted] ចាន់ ហៅ ចាំង កំពុងអង្គុយបន្ថែមទៀត ទើបធ្វើការឃាត់ខ្លួនតែម្ដង។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារនានានៅក្នុងសំណុំរឿង

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិចារណាតាមផ្លូវច្បាប់រួចរាល់ហើយ

**សាលាដំបូងខេត្តកណ្ដាល**

**យល់ឃើញថា**

១.តាមចំលើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្ត ភេទ ប្រុស, ឈ្មោះ [redacted] សក្កដា ហៅ កាក់ ភេទ ប្រុស, ឈ្មោះ [redacted] សក្ករ៉ាជ ហៅ ពៅ ភេទ ប្រុស និងឈ្មោះ [redacted] ចាន់ ហៅ ចាំង ភេទ ប្រុស រួមទាំងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងតាមការពិនិត្យឯកសារនានានៅក្នុងសំណុំរឿងឃើញថាៈ គឺពិតជាមានអំពើរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តិដោយជនសង្ស័យ ទាំង ៤នាក់ ខាងលើ ស្ថិតនៅក្នុងភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២០ ដូចអង្គហេតុនៃការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន។

២.ជនជាប់ចោទឈ្មោះ [redacted] ចាន់ ហៅ ចាំង ភេទ ប្រុស អាយុ ១៥ឆ្នាំ ជាអនីតិជន ដែលជាហេតុធ្វើឱ្យជនជាប់ចោទមានស្មារតី និង សមត្ថភាពមិនសូវគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ចំពោះមុខច្បាប់ពោលគឺ ជនជាប់ចោទ នៅជាអនីតិជននៅឡើយដែលអាចបង្ហាញថា ជនជាប់ចោទមិនមានស្មារតីពេញលក្ខណៈ

សម្បត្តិមិនគ្រប់គ្រាន់នៅក្នុងពេលប្រព្រឹត្តបទល្មើសឡើយ ។ រីឯជនជាប់ចោទឈ្មោះ ឈ្មោះ [redacted] ចិត្ត ភេទ ប្រុស, ឈ្មោះ [redacted] សក្កដា ហៅ កាក់ ភេទ ប្រុស និងឈ្មោះ [redacted] សក្ការ៉ាជ ហៅ ពៅ ភេទ ប្រុស គឺជានីតិជនដែលមានស្មារតីគ្រប់គ្រាន់ អាចយល់ដឹងចំពោះអំពើល្មើសដែលខ្លួនបានប្រព្រឹត្ត ។

៣.អំពើសត្យានុម័តរបស់ជនជាប់ចោទ ៖

៣.១.ឈ្មោះ [redacted] ចិត្ត ភេទ ប្រុស អាយុ ២១ឆ្នាំ បានឆ្លើយប្រហាក់ប្រហែលគ្នានៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងពេលសវនាការថា ខ្លួនដឹងពីបទចោទប្រកាន់របស់តំណាងអយ្យការមកលើខ្លួនរួចរាល់ហើយ ។ ខ្លួនមានថ្នាំញៀន ចំនួន ៤កញ្ចប់ក្នុងចំនោមថ្នាំញៀនដែលសមត្ថកិច្ចដកហូតបានសរុបដែលខ្លួនទិញ យកមកប្រើប្រាស់ ដោយឱ្យឈ្មោះ [redacted] ចាន់ ទៅយក ។ ខ្លួនមិនស្គាល់ឈ្មោះអ្នកលក់ថ្នាំញៀនទេ ទើបឱ្យឈ្មោះ [redacted] ចាន់ ទៅយកថ្នាំញៀននោះ ។ ខ្លួនជាអ្នកធ្វើការសំណង់ ដោយខ្លួនចេះប្រើប្រាស់ថ្នាំញៀននេះចំនួន ១ឆ្នាំ ទៅ ២ឆ្នាំ មកហើយ។ ក្នុង១ថ្ងៃ ខ្លួនជក់ថ្នាំញៀន ពី១ ទៅ ២កញ្ចប់ ដោយខ្លួនក៏ដឹងដែរថា ខ្លួនញៀននោះ មានទោស។ ខ្លួនឱ្យលុយទៅឈ្មោះ [redacted] ចាន់ ចំនួន ១០$ ទៅទិញថ្នាំញៀន ដោយខ្លួនទៅយកថ្នាំញៀនប្រហែលជាម៉ោង ៨ ទៅ ៩យប់ ដោយខ្លួនជិះកង់ទៅយកថ្នាំញៀន ។

៣.២.ឈ្មោះ [redacted] សក្កដា ហៅ កាក់ ភេទ ប្រុស អាយុ ២៤ឆ្នាំ បានឆ្លើយប្រហាក់ប្រហែលគ្នានៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងពេលសវនាការថា ខ្លួនដឹងពីបទចោទប្រកាន់របស់តំណាងអយ្យការមកលើខ្លួនរួចរាល់ហើយ ។ នៅក្នុងថ្ងៃកើតហេតុ ខ្លួនត្រូវឈ្មោះ [redacted] ចាន់ ប្រើឱ្យទៅដកលុយអ៊ិនធើណែត ដោយខ្លួនដកលុយយកទៅទិញបាយហូប ដោយថ្នាំញៀននោះ ជារបស់ឈ្មោះ [redacted] ចាន់ និងឈ្មោះ [redacted] ចិត្ត ។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀន បានចំនួន ១ដង ដោយខ្លួនជាអ្នកបើកលុយអ៊ិនធើណែតឱ្យគេ ។

៣.៣.ឈ្មោះ [redacted] សក្ការ៉ាធ ហៅ ពៅ ភេទ ប្រុស អាយុ ២១ឆ្នាំ បានឆ្លើយប្រហាក់ប្រហែលគ្នានៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងពេលសវនាការថា ខ្លួនដឹងពីបទចោទប្រកាន់របស់តំណាងអយ្យការមកលើខ្លួនរួចរាល់ហើយ ។ ខ្លួនមិនបានដឹងរឿងអ្វីទេ ចំពោះថ្នាំញៀននោះជារបស់ឈ្មោះ [redacted] ចិត្ត និងឈ្មោះ [redacted] ចាន់ ដោយពីមុនខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនដែរ ។

៣.៤.ឈ្មោះ [redacted] ចាន់ ហៅ ចាំង ភេទ ប្រុស អាយុ ១៥ឆ្នាំ បានឆ្លើយប្រហាក់ប្រហែលគ្នានៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងពេលសវនាការថា ខ្លួនមានថ្នាំញៀន ចំនួន ៥កញ្ចប់ដែលជារបស់ខ្លួន ។ លុយចំនួន ៤ម៉ឺនរៀល ជារបស់ឈ្មោះ [redacted] ចិត្ត ទិញបានចំនួន ៩កញ្ចប់ ដោយខ្លួនឱ្យ ចំនួន ៤ កញ្ចប់ទៅឈ្មោះ [redacted] ចិត្ត ដែលថ្នាំញៀននោះ ខ្លួនទិញពី [redacted]ជា ។ ខ្លួនជាអ្នកវាយភ្លេងខ្មែរ ដោយឈ្មោះ [redacted] ចិត្ត ធ្លាប់មកផឹកស្រាវផ្ទះរបស់ខ្លួន ហើយឱ្យលុយខ្លួនចាយ ។ ចំពោះឈ្មោះ [redacted] សក្កដា ហៅ កាក់ និងឈ្មោះ [redacted] សក្ការ៉ាធ មិនមានថ្នាំញៀន និងមិនដឹងរឿងអ្វីឡើយ ។

*តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្ត ភេទ ប្រុស, ឈ្មោះ [redacted] សក្កដា ហៅ កាក់ ភេទ ប្រុស, ឈ្មោះ [redacted] សក្ការ៉ាជ ហៅ ពៅ ភេទ ប្រុស និងឈ្មោះ [redacted] ចាន់ ហៅ ចាំង ភេទ ប្រុស និងរបាយការណ៍ពីមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងឯកសារផ្សេងៗទៀតដែលមាននៅក្នុងសំណុំរឿង អាចឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] ចិត្ត ភេទ ប្រុស និងជនជាប់ចោទឈ្មោះ [redacted] ចាន់ ហៅ ចាំង ភេទ ប្រុស ពិតជាបានប្រព្រឹត្តអំពើទិញថ្នាំញៀនដោយខុសច្បាប់យកមករក្សាទុកប្រាកដមែន ហើយស្របពេលនោះ ក៏ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងដកហូតបាននូវសារធាតុញៀនចំនួន ៩កញ្ចប់ ដែលជារបស់ឈ្មោះ [redacted] ចិត្ត និងឈ្មោះ [redacted]ន ចាន់ ហៅ ចាំង ។ ដោយឡែក ចំពោះឈ្មោះ [redacted] សក្កដា ហៅ កាក់ ភេទ ប្រុស និងឈ្មោះ [redacted] សកក្ការ៉ាធ*

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
កណ្ដាល. ថ្ងៃទី១៧...ខែ...ឆ្នាំ២០២០
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner

*ហៅ ពៅ ភេទ ប្រុស មិនបានរក្សាទុកនូវសារធាតុញៀនដោយខុសច្បាប់នោះឡើយ ពោលគឺ ជនជាប់ចោទទាំងពីរនាក់ គ្រាន់តែធ្លាប់បានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តែប៉ុណ្ណោះ ។*

៤.ទំនាក់ទំនងហេតុបច្ច័យនៃទង្វើរបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្ត ភេទ ប្រុស, ឈ្មោះ [redacted] សក្កដា ហៅ កាក់ ភេទ ប្រុស, ឈ្មោះ [redacted] សក្ករ៉ាជ ហៅ ពៅ ភេទ ប្រុស និងឈ្មោះ [redacted] ចាន់ ហៅ ចាំង ភេទ ប្រុស ដែលបានប្រព្រឹត្តខុសពីច្បាប់របស់សង្គម ពោលគឺ ជនជាប់ចោទទាំងបួននាក់ បាននាំគ្នាប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងទិញគ្រឿងញៀនមក ដើម្បីរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន វានាំឱ្យមានទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ។

៥.ធាតុអត្តនោម័តរបស់ជនជាប់ចោទ៖

៥.១.ជនជាប់ចោទឈ្មោះ [redacted] ចិត្ត ភេទ ប្រុស អាយុ ២១ឆ្នាំ គឺជានីតិជនដែលមានស្មារតី មានការយល់ដឹង ព្រមទាំងមានវិចារណញ្ញាណគ្រប់គ្រាន់ដែលអាចវិនិច្ឆ័យបានថា អំពើដែលខ្លួនប្រព្រឹត្ត គឺជាអំពើមិនល្អ ដែលសង្គមមិនទទួលស្គាល់ ហើយល្មើសទៅនឹងច្បាប់របស់ប្រទេសថែមទៀតផង។ ទោះបីដឹងថាយ៉ាងនេះក៏ដោយ ក៏ជនជាប់នៅតែមានឆន្ទៈក្នុងការប្រព្រឹត្តិបទល្មើសដែលច្បាប់បានហាមឃាត់ដដែល ពោលគឺ ជនជាប់ចោទមានចេតនាយ៉ាងពិតប្រាកដក្នុងការទិញថ្នាំញៀនដោយខុសច្បាប់យកមករក្សាទុក ដោយជនជាប់ចោទបានដឹងយ៉ាងច្បាស់លាស់ថា ទង្វើដែលខ្លួនបានប្រព្រឹត្តនេះ គឺជាទង្វើខុសច្បាប់ដែលច្បាប់ចាត់ទុកអំពើនេះថា ជាបទល្មើសរក្សាទុក ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិ មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៥.២.ជនជាប់ចោទឈ្មោះ [redacted] ចាន់ ហៅ ចាំង ភេទ ប្រុស អាយុ ១៥ឆ្នាំ គឺជាអនីតិជនដែលមិនមានស្មារតី ការយល់ដឹង ព្រមទាំងមានវិចារណញ្ញាណពុំទាន់គ្រប់គ្រាន់ដែលអាចវិនិច្ឆ័យបានថា អំពើដែលខ្លួនប្រព្រឹត្ត គឺជាអំពើមិនល្អ ដែលសង្គមមិនទទួលស្គាល់ ហើយល្មើសទៅនឹងច្បាប់របស់ប្រទេសនោះទេ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ជនជាប់មានឆន្ទៈក្នុងការប្រព្រឹត្តិបទល្មើសដែលច្បាប់បានហាមឃាត់ ពោលគឺ ជនជាប់ចោទមានចេតនាយ៉ាងពិតប្រាកដក្នុងការទិញថ្នាំញៀនដោយខុសច្បាប់យកមករក្សាទុក ចំនួន ៥កញ្ចប់។ ជនជាប់ចោទបានដឹងយ៉ាងច្បាស់លាស់ថា ទង្វើដែលខ្លួនបានប្រព្រឹត្តនេះ គឺជាទង្វើខុសច្បាប់ដែលច្បាប់ចាត់ទុកអំពើនេះថា ជាបទល្មើសរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន តាម បញ្ញត្តិ មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប៉ុន្តែដោយជនជាប់ចោទឈ្មោះ [redacted] ចាន់ ហៅ ចាំង ភេទ ប្រុស អាយុ ១៥ឆ្នាំ ជាអនីតិជន គប្បីតុលាការពិចារណាក្នុងការបន្ធូរបន្ថយទោសដល់ជនជាប់ចោទ។

៥.៣.ជនជាប់ចោទឈ្មោះ [redacted] សក្កដា ហៅ កាក់ ភេទ ប្រុស អាយុ ២៤ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] សក្ករ៉ាជ ហៅ ពៅ ភេទ ប្រុស អាយុ ២១ ឆ្នាំ គឺជានីតិជនដែលមានស្មារតី មានការយល់ដឹង ព្រមទាំងមានវិចារណញ្ញាណគ្រប់គ្រាន់ដែលអាចវិនិច្ឆ័យបានថា អំពើដែលខ្លួនប្រព្រឹត្ត គឺជាអំពើមិនល្អ ដែលសង្គមមិនទទួលស្គាល់ ហើយល្មើសទៅនឹងច្បាប់របស់ប្រទេសថែមទៀតផង។ ទោះបីជាយ៉ាងនេះក៏ដោយ គឺជនជាប់ចោទឈ្មោះ [redacted] សក្កដា ហៅ កាក់ និងឈ្មោះ [redacted] សក្ករ៉ាជ ហៅ ពៅ នៅតែទិញថ្នាំញៀនដោយខុសច្បាប់យកមកប្រើប្រាស់ថែមទៀតផង។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ គឺជនជាប់ចោទទាំងពីរនាក់បងប្អូនខាងលើ មិនបានរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនឡើយ ពោលគឺ នៅថ្ងៃកើតហេតុ ថ្នាំញៀនដែលសមត្ថកិច្ចដកហូតបាន ចំនួន ៩កញ្ចប់ គឺជារបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្ត ភេទ ប្រុស ចំនួន ៤កញ្ចប់ និងជារបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ ហៅ ចាំង ភេទ ប្រុស ចំនួន ៥កញ្ចប់ (ជនជាប់ចោទឈ្មោះ [redacted] ចិត្ត និងឈ្មោះ [redacted] ចាន់ បានទទួលស្គាល់នៅពេលសវនាការថាជារបស់ខ្លួនរួចហើយដែរ) ដែលមិនជារបស់ជនជាប់ចោទឈ្មោះ [redacted] សក្កដា ហៅ កាក់

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
កពុកាល. ថ្ងៃទី៣១... ខែ... ឆ្នាំ២០២០
ក្រឡាបញ្ជី
[redacted]

និងឈ្មោះ [redacted] សក្ករ៉ាធ ហៅ ពៅ នោះឡើយ គប្បីតុលាការពិចារណាក្នុងការកែប្រែបទចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] សក្កដា ហៅ កាក់ និងឈ្មោះ [redacted] សក្ករ៉ាធ ហៅ ពៅ ។

*យោងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្ត, ឈ្មោះ [redacted] សក្កដា ហៅ កាក់, ឈ្មោះ [redacted] សក្ករ៉ាធ ហៅ ពៅ និងឈ្មោះ [redacted] ចាន់ ហៅ ចាំង គឺពិតជាអាចឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] ចិត្ត និងជនជាប់ចោទឈ្មោះ [redacted] ចាន់ ហៅ ចាំង ពិតជាបាននាំគ្នារក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងបានប្រើប្រាស់គ្រឿងញៀនដោយខុសច្បាប់ប្រាកដមែន។ រីឯជនជាប់ចោទឈ្មោះ [redacted] សក្កដា ហៅ កាក់ និងឈ្មោះ [redacted] សក្ករ៉ាធ ហៅ ពៅ គឺគ្រាន់តែធ្លាប់ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតែប៉ុណ្ណោះ ដោយជនជាប់ចោទដែលជនជាប់ចោទទាំងពីរនាក់ មិនជាប់ពាក់ព័ន្ធនឹងករណីរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនឡើយ។*

៦.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្ត ភេទ ប្រុស, ឈ្មោះ [redacted] សក្កដា ហៅ កាក់ ភេទ ប្រុស, ឈ្មោះ [redacted] សក្ករ៉ាជ ហៅ ពៅ ភេទ ប្រុស និងឈ្មោះ [redacted] ចាន់ ហៅ ចាំង ភេទ ប្រុស ជាអំពើមួយដែលធ្វើអោយប៉ះពាល់ដល់សុខភាព សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ប៉ះពាល់ដល់សន្តិសុខសង្គមពិតប្រាកដមែន ។ ដោយឡែកចំពោះជនជាប់ចោទឈ្មោះ [redacted] សក្កដា ហៅ កាក់ និងឈ្មោះ [redacted] សក្ករ៉ាធ ហៅ ពៅ ត្រូវបានតំណាងអយ្យការ និងចៅក្រមស៊ើបសួរ ធ្វើការចោទប្រកាន់ពីបទ រក្សាទុក និងប្រើប្រាស់ដោយខុចច្បាប់នូវសារធាតុញៀន ដែលចំពោះទង្វើរបស់ជនជាប់ចោទ មិនមែនជាការរក្សាទុកដោយខុសច្បាប់នូវសាធាតុញៀនឡើយ ពីព្រោះថ្នាំញៀនទាំង៩កញ្ចប់នោះ មិនមែនជារបស់ជនជាប់ចោទទាំងពីរនាក់បងប្អូនទេ វាជារបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្ត ចំនួន ៤កញ្ចប់ និងជារបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ ហៅ ចាំង ចំនួន ៥កញ្ចប់ ហើយជនជាប់ចោទឈ្មោះ [redacted] ចិត្ត និងឈ្មោះ [redacted] ចាន់ ហៅ ចាំង ក៏បានទទួលស្គាល់ថាជារបស់ខ្លួននៅពេលសវនាការដែរ ដែលករណីនេះ គ្រាន់តែជាការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតែប៉ុណ្ណោះ គប្បីតុលាការធ្វើការកែប្រែបទចោទប្រកាន់ ពីបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន មកបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនវិញ។

៧.មានធាតុផ្សំនៃបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសទៅលើជនជាប់ចោទឈ្មោះ [redacted] ចិត្ត ភេទ ប្រុស និងឈ្មោះ [redacted] ចាន់ ហៅ ចាំង ភេទ ប្រុស ពីបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី ១១ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ រីឯជនជាប់ចោទឈ្មោះ [redacted] សក្កដា ហៅ កាក់ ភេទ ប្រុស និងឈ្មោះ [redacted] សក្ករ៉ាជ ហៅ ពៅ ភេទ ប្រុស មានធាតុផ្សំនៃបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោស ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី ១១ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៨.ការសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ផ្អែកតាមអង្គហេតុ និង ចំលើយផ្ទាល់របស់ជនជាប់ចោទ ព្រមទាំងភស្តុតាងផ្សេងៗ ចំពោះជនជាប់ចោទឈ្មោះ [redacted] សក្កដា ហៅ កាក់ និងឈ្មោះ [redacted] សក្ករ៉ាធ ហៅ ពៅ តំណាងអយ្យការស្នើសុំចៅក្រមសម្រេចតាមឆន្ទានុសិទ្ធិ ។ រីឯជនជាប់ចោទឈ្មោះ [redacted] ចិត្ត និងឈ្មោះ [redacted] ចាន់ ហៅ ចាំង គឺតំណាងអយ្យការ សូមតម្កល់ការចោទប្រកាន់ទុកនៅជាបានការដដែល។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

[redacted]

៩.ការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖ កូនក្តីរបស់ខ្លួនឈ្មោះ [redacted] សក្តដា ហៅ កាក់ និងឈ្មោះ [redacted] សក្តរ៉ាធ ហៅ ពៅ មិនជាប់ពាក់ព័ន្ធនឹងបទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនឡើយ សូមតុលាការសម្រេច ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន វិញ ។ រីឯកូនក្តីឈ្មោះ [redacted] ចាន់ ហៅ ចាំង សូមតុលាការសម្រេចបន្ធូបន្ថយទោសឱ្យកូនក្តីខ្លួនផង។

១០.វត្ថុចាប់យករួមមាន៖ ម្សៅក្រាមពណ៌សថ្លា ដែលសង្ស័យជាសារធាតុញៀន ចំនួន ៩ កញ្ចប់តូច ទម្ងន់ ០,៥៣ ក្រាម គប្បីតុលាការសម្រេចរឹបអូស និងបំផ្លាញចោល ។

១១.ជនជាប់ចោទទាំងបួននាក់បានសំណូមពរថា សូមអោយតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង គប្បីតុលាការពិចារណាពីការស្នើសុំនេះ ។

## ហេតុដូច្នេះ សាលាដំបូងខេត្តកណ្តាល

## វិនិច្ឆ័យសេចក្តី

១.កែប្រែបទចោទប្រកាន់ទៅលើជនជាប់ចោទ៖

១.១.ឈ្មោះ [redacted] សក្តដា ហៅ កាក់ (មានអត្តសញ្ញាណដូចខាងលើ) ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១.២.ឈ្មោះ សុផល សក្តរ៉ាធ ហៅ ពៅ (មានអត្តសញ្ញាណដូចខាងលើ) ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២.ផ្តន្ទាទោសជនជាប់ចោទ៖

ក.ឈ្មោះ [redacted] សក្តដា ហៅ កាក់ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ចំនួន ៦ខែ និងពិន័យជាប្រាក់ចំនួន ១០០,០០០៛(មួយសែន) រៀល ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ.ឈ្មោះ [redacted] សក្តរ៉ាធ ហៅ ពៅ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ចំនួន ៦ខែ និងពិន័យជាប្រាក់ចំនួន ១០០,០០០៛(មួយសែន) រៀល ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

គ.ឈ្មោះ [redacted] ចិត្ត ភេទ ប្រុស (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ចំនួន ២ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤,០០០,០០០៛(បួនលាន) រៀល ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
កណ្តាល. ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០២០
ក្រឡាបញ្ជី

[redacted]

ឃ.ឈ្មោះ [redacted] ចាន់ ហៅ ចាំង ភេទ ប្រុស អាយុ ១៥ឆ្នាំ ជាអនីតិជន (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ចំនួន ១ឆ្នាំ ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.វត្ថុតាងរួមមានម្សៅក្រាមពណ៌សថ្លា ដែលសង្ស័យជាសារធាតុញៀនចំនួន ៩ កញ្ចប់តូច ទម្ងន់ ០,៥៣ ក្រាម ត្រូវរឹបអូស និងបំផ្លាញចោល ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចិត្ត, ឈ្មោះ [redacted] សក្កដា ហៅ កាក់, ឈ្មោះ [redacted] សក្ករ៉ាជ ហៅ ពៅ និងឈ្មោះ [redacted] ចាន់ ហៅ ចាំង ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- | --- |
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១២កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កណ្តាល,ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

កណ្តាល, ថ្ងៃទី... ខែ... ឆ្នាំ២០២០

ក្រឡាបញ្ជី

[redacted]